ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងដាំដំណាំឆៃថាវ








# ដំណាំផែថាវ

## បទពិសោធន៍លើការអនុវត្តជាក់ស្តែងរបស់កសិករនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កសិករនៅស្រុកកៀនស្វាយ ខេត្តកណ្តាល និងកសិករនៅស្រុកភ្នំក្រវាញ ខេត្តពោធិសាត់

I-**<u>ស្ថានភាពទូទៅ</u>** ÷

**ផែថាវ** ជាបន្លែមួយប្រភេទក្នុងចំណោមបន្លែមើមជាច្រើនដែលកសិករកម្ពុជានិយមដាំ។ ផែថាវជាប្រភេទបន្លែមិនអាចខ្វះបានក្នុងម្ហូបអាហារប្រចាំថ្ងៃ ដោយសារផែថាវអាចធ្វើជាម្ហូបដោយការចម្អិនក៏បាន និងហូបឆៅក៏បានដូចជា ជ្រក់ ឬធ្វើផៃប៉ូវជាដើម។ តាមឯកសារស្រាវជ្រាវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផែថាវមានប្រភពកំណើតមកពីប្រទេសចិន។ ផែថាវជាបន្លែមើមសម្បូរដោយសារធាតុចិញ្ចឹម ដូចជា វីតាមីន និងសារធាតុរ៉ែជាច្រើនទៀត ដែលអាចជួយរក្សាតុល្យភាពរបបអាហារយ៉ាងល្អប្រសើរផងដែរ។ ដំណាំផែថាវ ងាយដាំ ជាបន្លែមើមដែលចូលចិត្តអាកាសធាតុត្រជាក់បន្តិចមិនក្តៅហែង ជាដំណាំដែលត្រូវការទឹកច្រើន។

II-**បច្ចេកទេសដាំដុះ** ÷

**១-រយៈពេលដាំដុះ ÷** ផែថាវមានពីរប្រភេទគឺពូជមានរយៈពេល ៦០ថ្ងៃ និង ៤៥ថ្ងៃ។ ពូជ ៦០ថ្ងៃ ដាំនៅរដូវប្រាំងព្រោះវាចាញ់ទឹក និងពូជ ៤៥ថ្ងៃ ដាំនៅរដូវវស្សា។

**២-រដូវកាលដាំដុះ ÷** យោងតាមឯកសាររបស់ក្រសួងកសិកម្ម ផែថាវជាប្រភេទដំណាំដែលអាចដុះលូតលាស់មិនប្រកាន់រដូវ អាចដាំបានស្ទើរពេញមួយឆ្នាំ ប៉ុន្តែការជ្រើសរើសរដូវដាំត្រូវជ្រើសរើសរដូវណាដែលមិនទាក់ទងទៅនឹងសត្វល្អិតចង្រៃស៊ីបំផ្លាញ។ រដូវដែលដាំដុះបានល្អគឺនៅរដូវទឹកសម្រកគិតចាប់ពីខែតុលា ដល់ខែមករា កាលណាពន្យាដល់ខែដល់ខែកុម្ភៈឬមិនា តែងទទួលរងនូវការបំផ្លាញពីសត្វល្អិតចង្រៃ។ ប៉ុន្តែ កសិករបានបញ្ជាក់ថា ការដាំដំណាំផែថាវបានល្អគឺចាប់ពីខែតុលា ដល់ខែកុម្ភៈតែប៉ុណ្ណោះ ក្រៅពីខែនេះគឺមិនអាចដាំបានឡើយ គឺដីស៊ី។

**៣-ការជ្រើសរើសពូជ ÷** ផែថាវ មិនទាន់អាចផលិតពូជនៅក្នុងប្រទេសបានទេ ដូចនេះពូជសុទ្ធតែនាំចូលពីក្រៅប្រទេស។ ពូជដែលត្រូវបានពិសោធន៍វាយតម្លៃទៅលើភាពបន្សាំក្នុងលក្ខខណ្ឌប្រទេសកម្ពុជា និងបានណែនាំឱ្យប្រើប្រាស់មាន÷

- ពូជ R 6197 និងពូជ Kao yuak ១៨មកពីប្រទេសថៃ ផលិតដោយក្រុមហ៊ុន East west seed
- ពូជ៥៥ថ្ងៃ មកពីប្រទេសថៃ ផលិតដោយក្រុមហ៊ុន Chea tai seed សញ្ញាយន្តហោះ
- ពូជ Everst (F1) មកពីប្រទេសជប៉ុន ផលិតដោយក្រុមហ៊ុន Takiiseed
- ពូជ Wang Jian មកពីចិនហុងកុង ផលិតដោយក្រុមហ៊ុន Hong Kong Field Friend Agriculture Unite Co. ដែលកំពុងពេញនិយមទូទាំងប្រទេសកម្ពុជាចាប់ពីឆ្នាំ២០០១មក។

**៤-ការរៀបចំដី÷**

ដើម្បីឱ្យដំណាំឆៃថាវកាន់តែឆាប់លូតលាស់ល្អ ត្រូវភ្ជួររាស់ដីយ៉ាងហោចណាស់ ៣ ទៅ ៤លើក ដែលធ្វើឱ្យដីធូរ ងាយជ្រាបទឹកបានល្អ។ គួរភ្ជួរដីជម្រៅពី ២៥-៣០ ស.ម រាស់បំបែកដីឱ្យល្អិតលាយជីលាមកសត្វ ផេះ ឬជីកំប៉ុស ហើយហាលដីទុកចោលរយៈពេល៧-១០ថ្ងៃ។ ការដាំឆៃថាវត្រូវតែលើករង បើដាំលើដីទំនាបអត់លើករង មិនល្អនោះទេ គឺតែងតែរលួយ ដូចនេះត្រូវតែដាំដោយលើកធ្វើជារង ព្រោះធ្វើឱ្យឆៃថាវមានមើមល្អ។ ការលើករង មានទទឹងពី១០០-១២០ ស.ម ចន្លោះពីរងមួយទៅរងមួយ ៥០ស.ម កម្ពស់រងរដូវវស្សាគួរលើករងកម្ពស់ពី២៥ ទៅ៣០ស.ម. និងរដូវប្រាំងគួរលើករងកម្ពស់ពី២០-២៥ស.ម.។ ឆៃថាវជាដំណាំដែលត្រូវការជីជាតិច្រើនប្រភេទជាពិសេសសារធាតុអាសូត(N) ផូស្វ័រ (P) ប៉ូតាស្យូម (K) និងកាល់ស្យូម ដូចនេះការប្រើប្រាស់ជីត្រូវជ្រើសរើសប្រភេទជីដែលមានសារធាតុ NPK ហើយដើម្បីឱ្យមានសារធាតុកាល់ស្យូមគឺប្រើលាមកសត្វ ជាពិសេសលាមកមាន់ដោយដាក់មុនដាំលើផ្ទៃដី១ហិកតាចំនួន ៨០០០-១០ ០០០គ.ក លាយជាមួយជីប្រភេទប៉ូតាស្យូមចំនួន ១៥០-២០០គ.ក បាចលើរងរួចរាស់លុបនិងកៀឱ្យស្មើមុនដាំ។



**៥-វិធីដាំ÷** ដាំដោយគ្រាប់ មុននឹងដាំត្រូវយកគ្រាប់ពូជដាក់ហាលថ្ងៃឱ្យក្តៅរយៈពេល ១-២ម៉ោង បន្ទាប់មកដាក់ត្រាំទឹកពី ៣-៤ម៉ោង និងលាងសម្អាតគ្រាប់ឱ្យបានច្រើនលើក ព្រមទាំងលាយថ្នាំការពារផ្សិតបន្តិចៗ (១គ.កគ្រាប់=២ក្រាមថ្នាំ)។ ការដាំដុះគឺយកគ្រាប់ពូជទៅដាំលើថ្នាលក្នុងជម្រៅ ២សង់ទីម៉ែត្រជាមធ្យមដាក់២គ្រាប់/គុម្ព ដោយរក្សាចន្លោះជួរ និងចន្លោះគុម្ព ២០x២០ ស.ម ក្រោយពីដាំហើយយកចំបើងគ្របលើផ្ទៃរងឱ្យបាន៧០ទៅ៨០% ដើម្បីការពារសំណើមនិងភាពហាប់ណែននៃដី ជួយឱ្យឆៃថាវដុះលូតលាស់បានល្អ ហើយក្រោយពេលដាំត្រូវស្រោចទឹកឱ្យជោគភ្លាម។

**៦-ការស្រោចស្រព ÷** ការស្រោចស្រពគឺធ្វើឡើងទៅតាមវគ្គនៃការលូតលាស់នៃដំណាំ÷

- វគ្គដុះពន្លក: ចាប់ពីដាំរហូតដល់កូនឆៃថាវដុះ១០០% វាត្រូវការសំណើមដីថេរ ត្រូវផ្តល់ទឹកព្រឹកល្ងាចតែមិនជោគជាំខ្លាំងទេ ដែលអាចនាំកូនដំណាំរលួយឫស។
- វគ្គលូតលាស់: ក្រោយពីដុះពន្លកបាន១០០% រយៈពេល៧-១០ថ្ងៃ កូនឆៃថាវដុះបានស្លឹក ២-៣សន្លឹក ត្រូវការទឹកកម្រិតមធ្យម
- វគ្គពង្រីកមើម: ក្រោយពីដាំបានពី ១៥-១៨ថ្ងៃ ឆៃថាវចាប់ផ្តើមពង្រីកគល់ប៉ោងបន្តិចៗ ពេលនេះវាត្រូវការទឹក និងសារធាតុចិញ្ចឹមកាន់តែកើនឡើងរហូតដល់ពេលប្រមូលផល ដូចនេះត្រូវការបង្កើនការស្រោចទឹកឱ្យខ្លាំងជាងវគ្គនានា។

**៧-ការជ្រុំដី និងដកស្មៅ÷** ត្រូវដកស្មៅ ជ្រុំគល់ និងដករំលស់កូនដោយទុកតែ១ដើម/គុម្ព។ ការជ្រុំដីធ្វើឡើងក្រោយពីដាំបានចំនួនពី១៥-១៨ថ្ងៃ ដោយផ្អាកស្រោចទឹក១ថ្ងៃដើម្បីឱ្យដីស្ងួត។

**៨-សត្វល្អិត÷ ដំណាំឆៃថាវជាធម្មតាតែងរងការបំផ្លាញពីសត្វល្អិតចង្រៃ រួមមាន÷**



- ដង្កូវយោលទោង: វាស៊ីបំផ្លាញជាលិកាស្លឹក ធ្វើឱ្យស្លឹកឆៃថាវលែងលូតលាស់
- ដង្កូវស៊ីរូងកំពូល: វាស៊ីត្រួយ
- ដង្កូវកាត់ដើម: វាកាត់ស៊ីដើម
- សត្វទាគូ: វាស៊ីបំផ្លាញឫស និងមើម

**-ប្រភេទថ្នាំកសិកម្មប្រើ ÷**

- សម្លាប់សត្វល្អិតប្រើថ្នាំគីមី **អាបាម៉ិចទីន - ទូនហ្វី**

**៧-ការដាក់ជីបំប៉ន ÷**



**ក/-តាមការអនុវត្តជាក់ស្តែងរបស់កសិករ ការដាក់ជីបំប៉នត្រូវអនុវត្តដូចខាងក្រោម (សម្រាប់ផ្ទៃដី១០ម៉ែ²)÷**

•**ការដាក់ជីបំប៉នលើកទី១** ក្រោយដាំបានរយៈពេល១០ថ្ងៃ÷ មេជី១គម្រប មេថ្នាំបណ្តេញសត្វល្អិត១គម្រប ថ្នាំមេអ័រម៉ូន ១គម្រប លាយជាមួយទឹក១០លីត្រ

•**ការដាក់ជីបំប៉នលើកទី២** ក្រោយដាំបាន១៥-១៨ថ្ងៃ÷ មេជី១គម្រប មេថ្នាំបណ្តេញសត្វល្អិត១គម្រប ថ្នាំមេអ័រម៉ូន ១គម្រប លាយជាមួយទឹក១០លីត្រ

•**ការដាក់ជីបំប៉នលើកទី៣** ក្រោយដាំបាន២៥-៣០ថ្ងៃ÷ មេជី១គម្រប មេថ្នាំបណ្តេញសត្វល្អិត១គម្រប ថ្នាំមេអ័រម៉ូន ២គម្រប លាយជាមួយទឹក១០លីត្រ

•**ការដាក់ជីបំប៉នលើកទី៤** ក្រោយដាំបាន៤០ថ្ងៃ÷ មេជី១គម្រប មេថ្នាំបណ្តេញសត្វល្អិត១គម្រប ថ្នាំមេអ័រម៉ូន ២គម្រប លាយជាមួយទឹក១០លីត្រ។

**ខ/-តាមលក្ខណៈបច្ចេកទេសរបស់ក្រសួងកសិកម្ម ការដាក់ជីត្រូវអនុវត្តដូចខាងក្រោម÷**

ការដាក់ជីបំប៉នត្រូវអនុវត្តចំនួន៤លើក÷

•ការដាក់ជីបំប៉នលើកទី១ ក្រោយដាំបាន១០ថ្ងៃ÷ ប្រើជីអ៊ុយរ៉េចំនួន ២៥-៣០ក្រាមលាយទឹក ២០លីត្រលើផ្ទៃដី១០ម៉ែ² (ក្នុង១ហិកតាប្រើចំនួន ២៥-៣០គ.ក) ហើយស្រោចទឹកលាងតាមក្រោយ។

•ការដាក់ជីបំប៉នលើកទី២ ក្រោយដាំបាន១៥-១៨ថ្ងៃ÷ ប្រើជី១៥ ១៥ ១៥ ចំនួន ២០០ក្រាម លើផ្ទៃដី១០ម៉ែ² (ក្នុង១ហិកតាប្រើចំនួន ២០០គ.ក) ដាក់តាមចន្លោះគុម្ពហើយជ្រុំដីលុបឱ្យជិត។

•ការដាក់ជីបំប៉នលើកទី៣ ក្រោយដាំបាន២៥-៣០ថ្ងៃ÷ ប្រើជីអ៊ុយរ៉េចំនួន ៤០-៥០ក្រាម លាយទឹក២០លីត្រ ស្រោចឱ្យជោគលើផ្ទៃដី១០ម៉ែ²ហើយស្រោចទឹកលាងតាមក្រោយ។

•ការដាក់ជីបំប៉នលើកទី៤ ក្រោយដាំបាន៤០ថ្ងៃ÷ ប្រើជី២ប្រភេទរួមគ្នាជីអ៊ុយរ៉េចំនួន ៣០គ.ក និងជីប៉ូតាស្យូម ៥០គ.ក (ផ្ទៃដី១ហិកតា) បញ្ចូលគ្នាហើយដាក់តាមចន្លោះគុម្ព ដើម្បីឱ្យឆៃថាវមានមើម ធំនិងមានគុណភាពល្អ។

**៨-ការប្រមូលផល÷** ដំណាំឆៃថាវអាចប្រមូលផលបានក្រោយពីដាំដុះបាន៤៥ ឬ ៦០ថ្ងៃ អាស្រ័យលើពូជ នៅពេលស្លឹករបស់វាប្រែពីបៃតងខ្ចី ទៅបៃតងចាស់ កំពូលត្រួយរបស់ដំណាំលែងលូត មើមរបស់វាប្រែពីសខ្ចីទៅប្រផេះ នោះជាដំណាក់កាលអាចប្រមូលផលបាន ហើយត្រូវប្រមូលផលម្តងទាំងអស់មិន

ទុកដូចដំណាំដទៃនោះឡើយព្រោះអាចធ្វើឱ្យឆៃថាវស្លោត ប៉ុន្តែបើប្រមូលផលនៅពេលឆៃថាវមិនទាន់គ្រប់អាយុកាលត្រឹមត្រូវនឹងធ្វើឱ្យបាត់បង់ទិន្នផល ព្រមទាំងមិនអាចរក្សាទុកបានយូរព្រោះវាខ្ចីពេក។ របៀបប្រមូលផលគឺដកឆៃថាវដាក់តម្រៀបនៅនឹងចម្ការ កាត់ស្លឹកចេញ ហើយជញ្ជូនទៅកាន់ទីត្រជាក់ មិនត្រូវដាក់ហាលថ្ងៃឡើយ។



**៩-ទិន្នផល ÷** ទិន្នផលអាស្រ័យទៅលើប្រភេទពូជ រដូវកាលដាំដុះ និងតំបន់ ដែលជាមធ្យមទទួលបាន ទិន្នផលពី ២៥-២៨ តោន/ហិកតា។

**១០-បញ្ហាប្រឈម ÷** ខ្វះទឹកស្រោចស្រព សត្វល្អិតចង្រៃ ថ្នាំនិងជីកសិកម្មអន់គុណភាព ហើយតម្លៃខ្ពស់ ពិបាករកកម្លាំងពលកម្ម ការប្រែប្រួលអាកាសធាតុ (ក្តៅខ្លាំង ត្រជាក់ ខ្យល់ ភ្លៀង មិនទៀងទាត់)។

**១១-កត្តាជោគជ័យ ÷** ជ្រើសរើសពូជល្អ ធន់នឹងអាកាសធាតុ ត្រូវជ្រើសរើសរដូវកាលដាំដុះដែលមានទីផ្សារនិងតម្លៃល្អ ត្រូវហាលដីឱ្យបានស្ងួតល្អ មុនបន្តដាំវគ្គបន្ទាប់។ ត្រូវប្រើថ្នាំសម្លាប់សត្វល្អិតនិងជីដែលមានប្រភពពីដេប៉ូលក់ មានច្បាប់អនុញ្ញាតត្រឹមត្រូវ មានការដាក់តាំងលក់សណ្តាប់ធ្នាប់ល្អ មិនឡូកឡំទំនិញអាចបរិភោគបាន និងត្រូវពិនិត្យសុពលភាពប្រើប្រាស់។ ការដាក់គ្រាប់ដាំ ត្រូវមានជួរត្រង់ល្អ សន្សំសំចៃគ្រាប់ពូជ និងដំណុះត្រង់ជួរ ងាយសម្អាតស្មៅ និងប្រើប្រាស់ថ្នាំ ជី មិនខ្ជះខ្ជាយ។ មុនពេលធ្វើការដាំដុះត្រូវធ្វើការពិភាក្សាជាមួយកសិករជុំវិញតំបន់របស់ខ្លួន ដើម្បីរៀបចំផែនការដាំដុះ និងប្រមូលផលមិនឱ្យស្របពេលគ្នា ជៀសវាងភាពជុញទីផ្សារ។

**III-ថ្លៃដើមផលិតកម្ម និងការវិភាគសេដ្ឋកិច្ច ÷**

**១/-កសិករសមាជិកសហគមន៍ក្តីសង្ឃឹមកសិករនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ÷**

-បទពិសោធន៍÷ ដាំដុះរយៈពេល១០ឆ្នាំ

-បច្ចេកទេស÷ ចេះតៗគ្នា និងទទួលបានការណែនាំបន្ថែមពីគម្រោង Aspire

-រយៈពេលដាំដុះរហូតបានប្រមូលផល÷ ៤៥ ថ្ងៃ

-រដូវកាលដាំដុះ÷ កសិករដែលដាំដុះពឹងរបបទឹកភ្លៀងគឺដាំក្នុងខែសីហា-កញ្ញាហើយក៏ជារដូវដែលសម្បូរដែរ។ កសិករដែលមានប្រព័ន្ធទឹកស្រោចស្រពគ្រប់គ្រាន់គឺដាំក្នុងខែឧសភា-មិថុនា ដែលជារដូវក្សត់និងលក់បានថ្លៃ។

-ទីផ្សារ÷ឈ្មួញចុះទិញដល់ចម្ការដោយការចំណាយលើកម្មករប្រមូលផលជាបន្ទុកអ្នកទិញ

-និន្នាការតម្លៃ÷ •តម្លៃឆៃថាវលេខ១ សម្រាប់ធ្វើជាបន្លែពី ៧០០៛-១២០០៛/គ.ក

•តម្លៃឆៃថាវលេខ២ សម្រាប់ធ្វើឆៃប៉ូវគឺទាបជាងតម្លៃឆៃថាវលេខ១ ៥០%

•ឆៃថាវលក់បានថ្លៃគឺនៅចន្លោះខែមេសា-មិថុនា (ជាខែក្សត់ទឹកដែលកសិករនៅតំបន់ខ្វះប្រភពទឹកមិនអាចដាំបាន)

-ផ្ទៃដីដាំដុះ÷ ៣០អា

-ទិន្នផលទទួលបាន÷ ៨ តោន ក្នុងនោះមើមឆៃថាវលេខ២ មានចំនួន៣០% នៃទិន្នផលសរុប ដោយសារជាតំបន់ដីក្រហម មិនសូវចាក់មើម និងមានប្រភេទតូចៗច្រើន

-តម្លៃជាមធ្យមឆ្នាំ២០២១÷ -ឆៃថាវលេខ១សម្រាប់ធ្វើជាបន្លែគឺ៨០០៛/គ.ក

-ឆៃថាវលេខ២ សម្រាប់ធ្វើជាឆៃប៉ូវគឺតម្លៃមធ្យម ៤០០៛/គ.ក។

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ (៛) ១ឯកត្តា | ទឹកប្រាក់សរុប (រៀល) | ចំនួនសារវិលោះ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុបពីការលក់ឆៃថាវ** | | | | | | **5,440,000** |
| ចំណូលពីការលក់មើមឆៃថាវលេខ១ | គ.ក | 5,600 | 800 | 4,480,000 | | 4,480,000 |
| ចំណូលពីការលក់មើមឆៃថាវលេខ២ | គ.ក | 2,400 | 400 | 960,000 | | 960,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **1,866,778** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **1,685,000** |
| ភ្ជួររាស់ + ធ្វើ | លើក | 3 | 45,000 | 135,000 | | 135,000 |
| ពូជ | កំប៉ុង | 10 | 10,000 | 100,000 | | 100,000 |
| ជីអ៊ុយរ៉េ | បាវ | 2 | 130,000 | 260,000 | | 260,000 |
| ថ្នាំសម្លាប់សត្វល្អិត + អ្នកបាញ់ | ដង | 2 | 300,000 | 600,000 | | 600,000 |

| | | | | | | |
|---|---|---|---|---|---|---|
| ថ្លៃកម្មករដកស្ទៅ (៥នាក់x២ដង) | នាក់/ដង | 10 | 30,000 | 300,000 | | 300,000 |
| ជួលកម្មករដាំ | នាក់ | 3 | 30,000 | 90,000 | | 90,000 |
| ប្រេងម៉ាស៊ីនបូមទឹក | កាន | 2 | 100,000 | 200,000 | | 200,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (រំលោះ ៣ទដ្ឋ/ឆ្នាំ)** | | | | **2,672,000** | | **181,778** |
| ម៉ាស៊ីនបូមទឹក៨សេស ប្រើបាន១០ឆ្នាំ | គ្រឿង | 1 | 2,000,000 | 2,000,000 | 30 | 66,667 |
| ក្បាលបូម (ប្រើបាន៥ឆ្នាំ) | គ្រឿង | 1 | 80,000 | 80,000 | 15 | 5,333 |
| ទុយោមេទំហំ៦០ស.មប្រើបាន៣ឆ្នាំ | ដើម | 15 | 10,000 | 150,000 | 9 | 16,667 |
| វ៉ាន (ប្រើបាន៣ឆ្នាំ) | សរុប | | | 100,000 | 9 | 11,111 |
| ទុយោសាច | ដុំ | 5 | 60,000 | 300,000 | 4 | 75,000 |
| ក្បាលវ៉ាន ៨០ស.ម | គ្រាប់ | 3 | 14,000 | 42,000 | 6 | 7,000 |
| **៣-ចំណេញសរុប** | | | | | | **3,573,222** |
| ថ្លៃដើម/គ.ក = ចំណាយសរុប/ទិន្នផល | | | | | | 233.35 |
| ចំណេញ/គ.ក = ចំណេញសរុប/ទិន្នផល | | | | | | 446.65 |

**-ដើមទុនសម្រាប់ការចាប់ផ្តើមដាំដំឡូងលើផ្ទៃដី ៣០អា÷**

| **បរិយាយ** | **ចំនួនទឹកប្រាក់ (រៀល)** |
|---|---|
| ចំណាយលើការដាំដុះ-ថែទាំ | 1,685,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 2,672,000 |
| **សរុប** | **4,357,000** |

**-លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ ÷**

| **ករណី** | ប្រភេទ ផែថាវ | តម្លៃ រៀល | ទិន្នផល គ.ក | ចំណូល រៀល | ចំណូលសរុប រៀល | ចំណាយសរុប រៀល | ចំណេញ រៀល | ចំណេញ % |
|---|---|---|---|---|---|---|---|---|
| **ករណីទី១** | លេខ១ | 700 | 5,600 | 3,920,000 | 4,760,000 | 1,866,778 | 2,893,222 | 155% |
| | លេខ២ | 350 | 2,400 | 840,000 | | | | |
| **ករណីទី២** | លេខ១ | 800 | 5,600 | 4,480,000 | 5,440,000 | 1,866,778 | 3,573,222 | 191% |
| | លេខ២ | 400 | 2,400 | 960,000 | | | | |
| **ករណីទី៣** | លេខ១ | 900 | 5,600 | 5,040,000 | 6,120,000 | 1,866,778 | 4,253,222 | 228% |
| | លេខ២ | 450 | 2,400 | 1,080,000 | | | | |
| **ករណីទី៤** | លេខ១ | 1,000 | 5,600 | 5,600,000 | 6,800,000 | 1,866,778 | 4,933,222 | 264% |
| | លេខ២ | 500 | 2,400 | 1,200,000 | | | | |
| **ករណីទី៥** | លេខ១ | 1,200 | 5,600 | 6,720,000 | 8,160,000 | 1,866,778 | 6,293,222 | 337% |
| | លេខ២ | 600 | 2,400 | 1,440,000 | | | | |

**ខ្សែច្រវាក់តម្លៃ** (ផ្លែថាវលេខ១ សម្រាប់ធ្វើជាបន្លែ)÷

**កសិករ**

-លក់ឱ្យឈ្មួញនៅចម្ការក្នុងតម្លៃ ៨០០ ៛/គ.ក

-ថ្លៃដើមផលិត ២៣៤៛/គ.ក

-ចំណេញ ៤៤៦៛/គ.ក

**ឈ្មួញកណ្តាល**

-បោះដុំក្នុងតម្លៃ ១៥០០ ៛/គ.ក

-ចំណេញចន្លោះពី ២០០៛ ទៅ ៣០០៛/គ.ក

(ទូទាត់ថ្លៃដឹក កម្មករ និងជួលកន្លែងដាក់ផលិតផលនៅផ្សារ)

**អ្នកលក់រាយនៅផ្សារ**

-លក់ក្នុងតម្លៃ ២៥០០-៣០០០៛/គ.ក

-ចំណេញចន្លោះពី ៥០០ រៀល ទៅ ៨០០ រៀល/គ.ក

(កាត់ខាតលើការលក់មិនអស់ រលួយចោល ថ្លៃលើកដាក់ និងជួលតូប)

២/-<u>**កសិករនៅភូមិវាល ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិសាត់÷**</u>

-ផ្ទៃដីដាំដុះ÷ ៥ ០០០ ម៉ែ២ (កន្លះហិកតា)

-ទិន្នផល÷ ១៤ តោន (= ២៨តោន/ហិកតា) -បទពិសោធន៍ដាំដុះ÷ ១០ឆ្នាំ

-បច្ចេកទេស÷ ចេះតពីឪពុកម្តាយ និងទទួលបានការណែនាំពីគម្រោង Cambodia Harvest

-រយៈពេលដាំដុះរហូតបានប្រមូលផល÷ ៤៥ ទៅ ៥៥ថ្ងៃ

-រដូវកាលដាំដុះ÷ ពីខែតុលា ដល់ខែកុម្ភៈ

-និន្នាកាតម្លៃលក់ផ្លែថាវ÷

- ផ្លែថាវប្រភេទលេខ១ តម្លៃទាបបំផុត ៥០០៛/គ.ក និងខ្ពស់បំផុត ១២០០៛/គ.ក នៅខែមករា-កុម្ភៈ (ផ្លែថាវដែលលក់បានថ្លៃគឺនៅក្នុងខែវិច្ឆិកា-ធ្នូ តម្លៃ ១៨០០៛/គ.ក ជាពេលដែលផ្លែថាវមិនសូវផ្តល់ផលល្អ ទិន្នផលទាបដោយសារមិនទាន់ដាច់ទឹកភ្លៀង។
- គម្លាតតម្លៃពីលេខ១ មកលេខ២ គឺ២០០៛/គ.ក
- ដោយសារដីតំបន់នេះជាប្រភេទដីល្បាយខ្សាច់ ផ្លែថាវប្រភេទលេខ២មាន ចំនួនតិចត្រឹម៤% ប៉ុណ្ណោះលើទិន្នផលសរុប
- តម្លៃជាមធ្យមនៅចុងឆ្នាំ២០២១ ចំពោះផ្លែថាវលេខ១សម្រាប់ធ្វើជាបន្លែគឺ៦០០៛/គ.ក រីឯផ្លែថាវលេខ២ សម្រាប់ធ្វើជាផ្លែប៉ូវគឺតម្លៃមធ្យម ៤០០៛/គ.ក។

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ១ឯកត្តា | ទឹកប្រាក់សរុប (រៀល) | ចំនួនសាររំលោះ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុបពីការលក់ផែថាវ** | | | | | | **8,288,000** |
| ចំណូលពីការលក់ផែថាវលេខ១ | គ.ក | 13,440 | 600 | 8,064,000 | | 8,064,000 |
| ចំណូលពីការលក់ផែថាវលេខ២ | គ.ក | 560 | 400 | 224,000 | | 224,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **3,151,417** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **2,625,000** |
| ភ្ជួររាស់ | លើក | 4 | 51,000 | 204,000 | | 204,000 |
| ពូនរង | លើក | 1 | 51,000 | 51,000 | | 51,000 |
| ពូជ (សញ្ញាឃ្លោក) | កំប៉ុង | 4 | 20,000 | 80,000 | | 80,000 |
| ជីលាមកគោ (កំប៉ុស) | គ.ក | 3,000 | 200 | 600,000 | | 600,000 |
| ជីអ៊ុយរ៉េ | បាវ | 2 | 110,000 | 220,000 | | 220,000 |
| ថ្នាំការពារដង្កូវ | ដប | 2 | 50,000 | 100,000 | | 100,000 |
| ថ្នាំសម្លាប់ស្មៅ | ដប | 2 | 25,000 | 50,000 | | 50,000 |
| ជួលកម្មករដាំ | នាក់ | 3 | 30,000 | 90,000 | | 90,000 |
| ប្រេងម៉ាស៊ូតបូមទឹក | លីត្រ | 120 | 3,400 | 408,000 | | 408,000 |
| កម្មករប្រមូលផល (៣នាក់x១០ថ្ងៃ) | នាក់/ថ្ងៃ | 30 | 25,000 | 750,000 | | 750,000 |
| សម្ភារៈវេចខ្ចប់ | គ.ក | 8 | 9,000 | 72,000 | | 72,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង១ឆ្នាំដាំបាន២វដ្ត)** | | | | **3,385,000** | | **526,417** |
| ម៉ាស៊ីនបូមទឹកផសេស ប្រើបាន៥ឆ្នាំ | គ្រឿង | 1 | 2,200,000 | 2,200,000 | 10 | 220,000 |
| ទុយោមេ ទំហំ ៨០ស.មប្រើបាន៣ឆ្នាំ | ដើម | 20 | 14,000 | 280,000 | 6 | 46,667 |
| ទុយោ ទំហំ ៥០ស.ម | ដុំ | 4 | 12,000 | 48,000 | 6 | 8,000 |
| ទុយោសាច | ដុំ | 7 | 65,000 | 455,000 | 4 | 113,750 |
| ក្បាលវ៉ាន ៨០ស.ម | គ្រាប់ | 3 | 14,000 | 42,000 | 6 | 7,000 |
| ក្បាលរ៉ូប៊ីណេ ៥០ស.ម | គ្រាប់ | 14 | 6,000 | 84,000 | 6 | 14,000 |
| ទុយោជ័រថ្លា | គ.ក | 20 | 9,000 | 180,000 | 2 | 90,000 |
| ក្បាលសាចផ្កាឈូក | គ្រាប់ | 2 | 6,000 | 12,000 | 2 | 6,000 |
| ក្បាលតេ ៨០-៥០ ស.ម | គ្រាប់ | 14 | 6,000 | 84,000 | 4 | 21,000 |
| **៣-ចំណេញសរុប** | | | | | | **5,136,583** |
| ថ្លៃដើម/គ.ក = ចំណាយសរុប/ទិន្នផល | | | | | | 225.10 |
| ចំណេញ/គ.ក = ចំណេញសរុប/ទិន្នផល | | | | | | 366.90 |

**-ដើមទុនសម្រាប់ការចាប់ផ្តើមដាំដំបូងលើផ្ទៃដី ៥០អា÷**

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ-ថែទាំ | 2,625,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 3,385,000 |
| **សរុប** | **6,010,000** |

**-លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ ÷**

| ករណី | ប្រភេទ ផ្លែថាវ | តម្លៃ រៀល | ទិន្នផល គ.ក | ចំណូល រៀល | ចំណូលសរុប រៀល | ចំណាយសរុប រៀល | ចំណេញ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | រៀល | % |
| **ករណីទី១** | លេខ១ | 500 | 13,440 | 6,720,000 | 6,888,000 | 3,151,417 | 3,736,583 | 119% |
| | លេខ២ | 300 | 560 | 168,000 | | | | |
| **ករណីទី២** | លេខ១ | 600 | 13,440 | 8,064,000 | 8,288,000 | 3,151,417 | 5,136,583 | 163% |
| | លេខ២ | 400 | 560 | 224,000 | | | | |
| **ករណីទី៣** | លេខ១ | 700 | 13,440 | 9,408,000 | 9,688,000 | 3,151,417 | 6,536,583 | 207% |
| | លេខ២ | 500 | 560 | 280,000 | | | | |
| **ករណីទី៤** | លេខ១ | 800 | 13,440 | 10,752,000 | 11,088,000 | 3,151,417 | 7,936,583 | 252% |
| | លេខ២ | 600 | 560 | 336,000 | | | | |
| **ករណីទី៥** | លេខ១ | 900 | 13,440 | 12,096,000 | 12,488,000 | 3,151,417 | 9,336,583 | 296% |
| | លេខ២ | 700 | 560 | 392,000 | | | | |

**ខ្សែច្រវាក់តម្លៃ** (ផ្លែថាវលេខ១ សម្រាប់ធ្វើជាបន្លែ ) ÷

**កសិករ**

-លក់ឱ្យឈ្មួញនៅចម្ការក្នុងតម្លៃ ៦០០ ៛/គ.ក

-ថ្លៃដើមផលិត ២២៥.១០៛/គ.ក

-ចំណេញ ៣៦៦.៩០៛/គ.ក

**ឈ្មួញកណ្តាល**

**(បោះដុំនៅពោធិសាត់ និងបាត់ដំបង)**

-បោះដុំក្នុងតម្លៃ ១,០០០-១,១០០ ៛/គ.ក

-ចំណេញចន្លោះពី ២០០៛ ទៅ ៣០០៛/គ.ក

(ថ្លៃដឹក+១០០៛/គ.ក, កម្មករ +៥០៛/គ.កនិង ជួលកន្លែង +៥០៛/គ.ក)

**អ្នកលក់រាយនៅផ្សារ**

-លក់ក្នុងតម្លៃ ១,៨០០-២,០០០៛/គ.ក

-ចំណេញចន្លោះពី ៥០០ រៀល ទៅ ៨០០ រៀល/គ.ក

(កាត់ខាតលើការលក់មិនអស់ រលួយចោល ថ្លៃលើកដាក់ និងជួលតូប)

**៣/-កសិករនៅភូមិស្ទឹង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ÷**

-ផ្ទៃដីដាំដុះ÷ ១ ហិកតា

-ទិន្នផល÷ ២១ តោន

-បទពិសោធន៍÷ ដាំដុះរយៈពេល៧ឆ្នាំ -បច្ចេកទេស÷ ចេះតៗគ្នា

-រយៈពេលដាំដុះរហូតបានប្រមូលផល÷ ៤៥ ទៅ ៦៥ថ្ងៃ

-រដូវកាលដាំដុះ÷ ពីខែតុលា ដល់ខែកុម្ភៈ

-និន្នាកាតម្លៃលក់ផ្លែថាវ÷ • ផ្លែថាវលេខ១÷ ៧០០៛-១១០០៛/គ.ក

• ផ្លែថាវលេខ២÷ ៣៥០៛-៧០០៛/គ.ក

-តម្លៃជាមធ្យមនៅមករាឆ្នាំ២០២២ ចំពោះផ្លែថាវលេខ១សម្រាប់ធ្វើជាបន្លែគឺ៩០០៛/គ.ក រីឯផ្លែថាវលេខ២ សម្រាប់ធ្វើជាផ្លែប៉ូវគឺតម្លៃមធ្យម ៥០០៛/គ.ក និងជាមធ្យមគឺស្មើនឹង៣០% លើទិន្នផលសរុប។

| បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ ១ឯកត្តា | ទឹកប្រាក់សរុប (រៀល) | ចំនួនសារវិលោះ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុប** | | | | | | **16,380,000** |
| ចំណូលពីការលក់ផ្លែថាវលេខ១ | គ.ក | 14,700 | 900 | 13,230,000 | | 13,230,000 |
| ចំណូលពីការលក់ផ្លែថាវលេខ២ | គ.ក | 6,300 | 500 | 3,150,000 | | 3,150,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **10,135,667** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **9,689,000** |
| ភ្ជួររាស់ | លើក | 3 | 180,000 | 540,000 | | 540,000 |
| ពូនរង | លើក | 1 | 100,000 | 100,000 | | 100,000 |
| ពូជ (សញ្ញាឃ្លោក) | កំប៉ុង | 8 | 25,000 | 200,000 | | 200,000 |
| ជីលាមកគោ (កំប៉ុស) | គ.ក | 8,000 | 500 | 4,000,000 | | 4,000,000 |
| ជីទ្រាប់បាត DAP | បាវ | 3 | 128,000 | 384,000 | | 384,000 |
| ជីអ៊ុយរ៉េ | បាវ | 2 | 120,000 | 240,000 | | 240,000 |
| ថ្នាំការពារដង្កូវ | ដប | 4 | 50,000 | 200,000 | | 200,000 |
| ជួលកម្មករដាំ | នាក់ | 5 | 30,000 | 150,000 | | 150,000 |
| ប្រេងម៉ាស៊ូតបូមទឹក | លីត្រ | 350 | 3,400 | 1,190,000 | | 1,190,000 |
| កម្មករថែទាំ (១វគ្គ៣ដង x ៥នាក់) | នាក់/ដង | 15 | 30,000 | 450,000 | | 450,000 |
| កម្មករប្រមូលផល (គិតជាតោន) | តោន | 21 | 100,000 | 2,100,000 | | 2,100,000 |
| សម្ភារៈវេចខ្ចប់ | គ.ក | 15 | 9,000 | 135,000 | | 135,000 |

| | | | | | | |
|---|---|---|---|---|---|---|
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង១ឆ្នាំដាំបាន២រដូវ)** | | | | **3,186,000** | | **446,667** |
| ម៉ាស៊ីនបូមទឹក៨សេស ប្រើបាន៥ឆ្នាំ | គ្រឿង | 1 | 2,000,000 | 2,000,000 | 10 | 200,000 |
| ទុយោមេ ទំហំ៨០ស.ម ប្រើបាន៣ឆ្នាំ | ដើម | 30 | 14,000 | 420,000 | 6 | 70,000 |
| ទុយោ ទំហំ ៥០ស.ម | ដុំ | 10 | 13,000 | 130,000 | 6 | 21,667 |
| ក្បាលវ៉ាន ៨០ស.ម | គ្រាប់ | 6 | 14,000 | 84,000 | 6 | 14,000 |
| ទុយោជ័រ | គ.ក | 40 | 9,000 | 360,000 | 4 | 90,000 |
| ក្បាលសាចផ្កាឈូក | គ្រាប់ | 2 | 6,000 | 12,000 | 2 | 6,000 |
| ក្បាលតេ ៨០-៥០ ស.ម | គ្រាប់ | 30 | 6,000 | 180,000 | 4 | 45,000 |
| **៣-ចំណេញសរុប** | | | | | | **6,244,333** |
| ថ្លៃដើម/ គ.ក = ចំណាយសរុប/ទិន្នផល | | | | | | 362.99 |
| ចំណេញ/ គ.ក = ចំណេញសរុប/ទិន្នផល | | | | | | 223.01 |

**-ដើមទុនសម្រាប់ការចាប់ផ្តើមដាំដំបូងលើផ្ទៃដី ១ហិកតា÷**

| បរិយាយ | ចំនួនទឹកប្រាក់ (រៀល) |
|---|---|
| ចំណាយលើការដាំដុះ-ថែទាំ | 9,689,000 |
| ចំណាយលើប្រព័ន្ធស្រោចស្រព | 3,186,000 |
| សរុប | **12,875,000** |

**-លទ្ធភាពចំណេញដោយផ្អែកលើនិន្នាការតម្លៃ ÷**

| ករណី | ប្រភេទ | តម្លៃ រៀល | ទិន្នផល គ.ក | ចំណូល រៀល | ចំណូលសរុប រៀល | ចំណាយសរុប រៀល | ចំណេញ រៀល | ចំណេញ % |
|---|---|---|---|---|---|---|---|---|
| **ករណីទី១** | លេខ១ | 700 | 14,700 | 10,290,000 | 12,495,000 | 10,135,667 | 2,359,333 | 23% |
| | លេខ២ | 350 | 6,300 | 2,205,000 | | | | |
| **ករណីទី២** | លេខ១ | 800 | 14,700 | 11,760,000 | 14,595,000 | 10,135,667 | 4,459,333 | 44% |
| | លេខ២ | 450 | 6,300 | 2,835,000 | | | | |
| **ករណីទី៣** | លេខ១ | 900 | 14,700 | 13,230,000 | 16,380,000 | 10,135,667 | 6,244,333 | 62% |
| | លេខ២ | 500 | 6,300 | 3,150,000 | | | | |
| **ករណីទី៤** | លេខ១ | 1,000 | 14,700 | 14,700,000 | 18,480,000 | 10,135,667 | 8,344,333 | 82% |
| | លេខ២ | 600 | 6,300 | 3,780,000 | | | | |
| **ករណីទី៥** | លេខ១ | 1,100 | 14,700 | 16,170,000 | 20,580,000 | 10,135,667 | 10,444,333 | 103% |
| | លេខ២ | 700 | 6,300 | 4,410,000 | | | | |

**IV-ចំណុចខ្លាំង÷**

-មានតម្រូវការទីផ្សារ និងអាចលក់បានគ្រប់រដូវ ដោយឈ្មួញចុះមកប្រមូលទិញដល់ចំការ

-អាចរកបានប្រាក់ចំណូលបានសមរម្យ។ ផ្អែកតាមទិន្នផល និងនិន្នាការតម្លៃ ទោះបីតម្លៃលក់ផ្លែថាវទាបបំផុតក៏កសិករនៅតែទទួលបានផលចំណេញដែរគ្រាន់តែចំណេញតិច ដែលកសិករចាត់ទុកថាជាការខាតបង់។

-ជាប្រភេទបន្លែដែលងាយដាំ និងឆាប់ឱ្យផល

-មានបទពិសោធន៍ក្នុងការធ្វើចំការរយៈពេលយូរឆ្នាំ

**V-បញ្ហាប្រឈម÷**

-រដូវខ្លះទិន្នផលដែលទទួលបានគឺទាបជាងការរំពឹងទុកដែលមូលហេតុបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ដូចជារាំងពេក ត្រជាក់ពេក ភ្លៀងច្រើនពេក

-គុណភាពដីនៅតំបន់ខ្លះគឺលែងដាំបានទៀតហើយ (ដីស៊ីមើម) ដូចជានៅតំបន់ស្រុកស្អាង

-ខ្វះប្រភពទឹកសម្រាប់ស្រោចស្រពសម្រាប់ការដាំដុះនៅរដូវប្រាំង

-ផ្លែថាវនាំចូលពីប្រទេសវៀតណាមមានតម្លៃថោកជាងផ្លែថាវក្នុងស្រុក

-ថ្លៃដើមផលិតកម្មខ្ពស់ដោយសារតម្លៃប្រេងឥន្ទនៈ និងអគ្គិសនីសម្រាប់ប្រើប្រាស់បូមទឹកនៅមានតម្លៃខ្ពស់

-ការឡើងថ្លៃនៃធាតុចូលកសិកម្ម ជី និងថ្នាំសម្លាប់សត្វល្អិត